អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ការតាំងពិព័រណ៍ចល័តស្តីពី "អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម" និង កិច្ចសន្ទនាអន្តរជំនាន់

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងរៀបចំ ការតាំងពិព័រចល័ស្តីពី អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម និង កិច្ចសន្ទនាអន្តរជំនាន់ នៅថ្ងៃទី ១៣-១៤ ខែ កញ្ញា ឆ្នាំ ២០១៧ ចាប់ពីម៉ោង ៩៖០០ ដល់ ម៉ោង ៧៖០០ ល្ងាច នៅសាលមហោស្រពខេត្តតាកែវ ស្ថិតនៅទីរួមខេត្តតាកែវ ក្នុងគោលបំណង (១)ផ្តល់ឱកាសឱ្យអ្នកចូលរួមបានដឹងពីរឿងរ៉ាវឈឺចាប់របស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (២) លើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះ តាមរយៈការសន្ទនាអន្តរជំនាន់ ដោយផ្តល់ឱកាសឱ្យពួកគាត់បានជួប និងចែករំលែកបទពិសោធន៍ស្តីពីការបង្ខំឱ្យរៀបការក្នុងរបបខ្មែរក្រហមដល់យុវជន (៣) បង្កើនការយល់ដឹងដល់យុវជន និងសាធារណៈជននៅតាមសហគមន៍ឱ្យបានស្វែងយល់បន្ថែមពីអំពើហិង្សាយេនឌ័រក្នុងសម័យខ្មែរក្រហម និងលើកទឹកចិត្តអោយពួកគេចូលរួមប្រឆាំងនឹងអំពើហិង្សាយេនឌ័រនៅសង្គមកម្ពុជានាពេលបច្ចុប្បន្ន និងជម្រុញឱ្យមានការ គាំទ្រជនរងគ្រោះពីសហគមន៍។

កម្មវិធីនេះនឹងមានការចូលរួមពីមន្ត្រីនៃ អ.វ.ត.ក ម្ចាស់ជំនួយ ជនរងគ្រោះដោយការបង្ខំឱ្យរៀបការក្នុងរបបខ្មែរក្រហម អាជ្ញាធរ និងនិស្សិតមកពីសាកលវិទ្យាល័យបៀលប្រាយ យុវជនក្នុងសហគមន៍ និងអង្គការដៃគូនានាមានដូចជា អង្គការចិត្តសង្គមអន្តរវប្បធម៌ (ធីភីអូ) មជ្ឈមណ្ឌលហាន់ដា និង ក្រុមសិល្បៈសុភីលីន។

ការតាំងពិព័រណ៍ចល័ត និង កិច្ចសន្ទនាអន្តរជំនាន់នេះ ស្ថិតក្រោមគម្រោងក្រៅបច្ចេកទេសតុលាការ៖ "ការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌របស់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម" ដែលទទួលមូលនិធិពីអង្គការសហប្រជាជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី (United Nations Trust Fund on Violence against Women - UNTF) សម្រាប់ការអនុវត្តក្នុងរយៈពេលបីឆ្នាំចាប់ពីខែមករា ឆ្នាំ២០១៦ ដល់ ខែធ្នូ ឆ្នាំ២០១៨។

**ព័ត៌មានសម្រាប់ធ្វើទំនាក់ទំនងជាមួយអង្គភាពគាំពារជនរងគ្រោះ**

**លោក ហង្ស វណ្ណៈ**
ប្រធានអង្គភាពគាំពារជនរងគ្រោះ នៃអ.វ.ត.ក
ទូរស័ព្ទៈ +៨៥៥ (0) ២៣ ៨៦១ ៨២២
អ៊ីមែល៖ hang.vannak@eccc.gov.kh

ព័ត៌មានសម្រាប់ទំនាក់ទំនងផ្នែកសារព័ត៌មាន

លោក នេត្រ ភក្ត្រា
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖+៨៥៥ (0) ១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ៨៦១ ៥៦៤
អ៊ីមែល៖ neth.pheaktra@eccc.gov.kh

លោកស្រី Hayat Abu-Saleh
មន្ត្រីព័ត៌មានសាធារណៈ
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ៩៣៦
ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ៨៦0 ១៩១
អ៊ីមែល៖ abusaleh@un.org